ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# ព័ត៌មាន

កាលពីថ្ងៃទី១១-១៣ ខែធ្នូ ឆ្នាំ២០១៤ គណៈប្រតិភូនៃធនាគារជាតិនៃកម្ពុជា ដឹកនាំដោយ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងគណៈប្រតិភូនៃធនាគារកណ្តាលឡាវ ដឹកនាំដោយ ឯកឧត្តម Somphao Phaysith ទេសាភិបាលធនាគារកណ្តាលឡាវ បានជួបប្រជុំទ្វេភាគីប្រចាំឆ្នាំនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជា-មានិតឡាវ ។ កិច្ចប្រជុំទ្វេភាគីនេះ បានចាប់ផ្តើមឡើងតាំងពីឆ្នាំ២០១០ ហើយមានគោលបំណងដើម្បីរឹតចំណង មិត្តភាព និងកិច្ចសហប្រតិបត្តិការជាប្រពៃណីឱ្យកាន់តែជិតស្និទ្ធ រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលឡាវ និងប្រជាជនទាំងពីរដែលមានតាំងពីយូរលង់ណាស់មកហើយ ។

គណៈប្រតិភូទាំងពីរបានធ្វើការពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ស្តីពី វឌ្ឍនភាពថ្មីៗ បញ្ហាប្រឈម និងដំណោះស្រាយ ទាក់ទងនឹងស្ថានភាពសេដ្ឋកិច្ច និងការត្រួតពិនិត្យធនាគាររបស់ធនាគារកណ្តាលទាំងពីរ ។ អង្គប្រជុំក៏បានស្វែងរកផងដែរនូវលទ្ធភាពដែលស្ថាប័នទាំងពីរនឹងបង្កើនកិច្ចសហប្រតិបត្តិការ ព្រមទាំងចែករំលែកចំណេះដឹង និងបទពិសោធន៍ រវាងគ្នានិងគ្នា នាពេលអនាគត ។

ធនាគារកណ្តាលទាំងពីរ បានអបអរសាទរនឹងវឌ្ឍនភាពនៃវិស័យសេដ្ឋកិច្ចនិងធនាគារ នៅក្នុងប្រទេសទាំងពីរ និងបានកត់សម្គាល់នូវការរីកចម្រើនជាបន្តបន្ទាប់នៃកិច្ចសហប្រតិបត្តិការទ្វេភាគីនារយៈពេលកន្លងមក ជាពិសេស នៅឆ្នាំ២០១៤ នេះ ។ គណៈប្រតិភូទាំងពីរបានប្តេជ្ញាពង្រឹងនិងពង្រីកជាប្រចាំនូវកិច្ចសហប្រតិបត្តិការ រវាងស្ថាប័នទាំងពីរ សំដៅរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ ឱ្យបានរឹងមាំ ជាប្រយោជន៍ដល់ប្រទេសនិងប្រជាជនទាំងពីរ ដែលឋិតនៅភូមិផងរបងជាមួយ ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧